ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៨១

ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

សាលដីកា

លេខ: ៥២ "I"

ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រមរបាយការណ៍

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ៣៨៦ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់លោក [redacted] ទី ជាមេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] ម៉ីយីង [redacted] MEI YING) និងជនត្រូវចោទឈ្មោះ [redacted] ឈ្យយជី ([redacted] CHUI ZHI) ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៩៤ "ក្រ.III.ស.អ" ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមាន ៖

-ជនត្រូវចោទ ៖

១.ឈ្មោះ [redacted] MEI YING ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិចិន មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅប្រទេសចិន ទីលំនៅបច្ចុប្បន្ន [redacted] ខេត្តព្រះសីហនុ ឪពុកឈ្មោះ



Scanned with CamScanner

[redacted]"វ" ម្តាយឈ្មោះ [redacted]"វ" នៅលើវ ទោសពីមុនគ្មាន (ក្នុងឃុំ) ។ (អ្នកប្តឹងសាទុក្ខ)

២.ឈ្មោះ [redacted] ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិចិន មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើតនៅប្រទេសចិន ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted]"វ" ម្តាយឈ្មោះ [redacted]"វ" នៅលើវ ទោសពីមុនគ្មាន (ក្នុងឃុំ) ។ (អ្នកប្តឹងសាទុក្ខ)

លោក [redacted]ទី ជាមេធាវីការពារសិទ្ធិ ។

**ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ ៖** អំពើលួច (ប៉ុនប៉ង) ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ ។

**អំពីអង្គហេតុ ៖**

តាមរបាយការណ៍លេខ ១២៩០ របក/១៩ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ការិយាល័យកណ្តាលនគរបាលព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានឱ្យដឹងថា កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ វេលាម៉ោង ០១ និង ០០នាទី រំលងអាធ្រាត្រ នៅពេលកម្លាំងជំនាញល្បាតផែននគរបាលព្រហ្មទណ្ឌ កំពុងល្បាតក៏បានប្រទះឃើញមានជនជាតិចិនចំនួន ២នាក់ បានឈប់ម៉ូតូ ០១គ្រឿង ម៉ាក YAMAHA ពណ៌ខ្មៅ គ្មានស្លាកលេខ នៅម្តុំត្រីម្ហូប៊ីន មុខផ្ទះរបស់គេស្ថិតនៅភូមិ២ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ បើកកែបម៉ូតូយកដែកគាស់ចេញមកបម្រុងធ្វើសកម្មភាពគាស់ទ្វារផ្ទះ ភ្លាមនោះជនសង្ស័យទាំង ២នាក់ បានឃើញសមត្ថកិច្ចហើយបានយកសម្ភារៈទុកវិញរួចក៏បើកម៉ូតូរត់គេច ឃើញដូចនេះសមត្ថកិច្ចយើងក៏ដេញតាមរហូតឈានដល់ការឃាត់ខ្លួនជនសង្ស័យទាំង២នាក់នោះ និងធ្វើការឆែកឆេររកឃើញសម្ភារៈមួយចំនួនរួមមាន ដែកគាស់ ២ដើម, ទល្វីស ២ដើម, កន្ត្រៃកាត់សោរ ឬច្រវ៉ាក់, ស្រោមដៃ ២គូរ, ម៉ាស់ ២ដុំ និងមួកពណ៌ខ្មៅ ។ ក្រោយពីឃាត់ខ្លួនជនសង្ស័យយកមកសួរនាំរួចហើយ មន្ត្រីនគរបាលយុត្តិធម៌ ក៏បានកសាងសំណុំរឿងបញ្ជូនជនសង្ស័យព្រមទាំងវត្ថុតាងមកកាន់តុលាការ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

-បានឃើញ ដីកាសម្រេចឱ្យឃុំខ្លួនជាបណ្តោះអាសន្នលេខ ៤៦៩៧ តពង/១៩ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

ឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted]MEI YING ភេទប្រុស ជនជាតិចិន ជាបណ្តោះអាសន្នរយៈពេលអតិបរមា ០៣(បី)ខែ ។



Scanned with CamScanner

-បានឃើញ ដីកាសម្រេចឱ្យឃុំខ្លួនជាបណ្ដោះអាសន្នលេខ ៤៦៩៩ តពង/១៩ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

ឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] CHUI ZHI ភេទប្រុស ជនជាតិចិន ជាបណ្ដោះអាសន្នរយៈពេលអតិបរមា ០៣(បី)ខែ ។

-បានឃើញ ពាក្យសុំដោះលែងឱ្យកូនក្ដីនៅក្រៅឃុំលេខ ៥០/១៩ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] ទី ជាមេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] MEI YING និងឈ្មោះ [redacted] CHUI ZHI ដែលប្ដឹងមិនសុខចិត្តនឹងដីកាសម្រេចឱ្យឃុំខ្លួនជាបណ្ដោះអាសន្នលេខ ៤៦៩៧ តពង/១៩ និងលេខ ៤៦៩៩ តពង/១៩ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ ពាក្យសុំសម្រេចជំនួសលេខ ៥១/១៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់លោក [redacted] ទី ជាមេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] MEI YING និងឈ្មោះ [redacted] CHUI ZHI ស្នើសុំឱ្យសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ សម្រេចជំនួសចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ លើពាក្យសុំដោះលែងឱ្យកូនក្ដីនៅក្រៅឃុំលេខ ៥០/១៩ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៩៤ "ក្រ.III.ស.អ" ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១.ទទួលពាក្យសុំសម្រេចជំនួសលេខ ៥១/១៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ទី ជាមេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] MEI XING និងឈ្មោះ [redacted] CHUI ZHI គឺត្រឹមត្រូវ តាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.មិនអនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] MEI XING ភេទប្រុស អាយុ២៩ឆ្នាំ និងឈ្មោះ [redacted] CHUI ZHI ភេទប្រុស អាយុ២៤ឆ្នាំ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ អំពើលួច (ប៉ុនប៉ង) ប្រព្រឹត្តនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ មាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ នៅក្រៅឃុំបណ្ដោះអាសន្នឡើយ ។

៣.សាលដីកានេះ បានប្រកាសជាអសាធារណៈ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ បើកសិទ្ធិប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ៣៨៦ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់លោក [redacted] ទី ជាមេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] ម៉ីយីង ([redacted] Mei Ying) និងជនត្រូវចោទឈ្មោះ [redacted] ឈ្វយជី ([redacted]



Scanned with CamScanner

Chui Zhi) ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៩៤ "ក្រ.III.ស.អ" ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា ៖

-យល់ឃើញថា ជនត្រូវចោទឈ្មោះ [redacted] MEI YING (ជនជាតិចិន) និងឈ្មោះ [redacted] CHUI ZHI (ជនជាតិចិន) ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ អំពើលួច (ប៉ុនប៉ង) ប្រព្រឹត្ត នៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៣៥៣ មាត្រា ៣៥៦ និងមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ ។

-យល់ឃើញថា សាលាឧទ្ធរណ៍បានសម្រេចលើពាក្យសុំសម្រេចជំនួសលេខ ៥១/១៩ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ របស់មេធាវី [redacted] ទី មិនអនុញ្ញាតឱ្យជនត្រូវចោទឈ្មោះ [redacted] MEI YING និងឈ្មោះ [redacted] CHUI ZHI នៅក្រៅឃុំបណ្តោះអាសន្នឡើយ ។

-យល់ឃើញថា សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះមានសំអាងហេតុស្របតាមមាត្រា ២០៤ និងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយគប្បីតម្កល់ទុកជាបានការ ។ ហេតុដូច្នេះ តំណាងមហាអយ្យការ សូមទុកជូនក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៨៦ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់លោក [redacted] ទី ជាមេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] ម៉ីយីង ([redacted] Mei Ying) និងជនត្រូវចោទឈ្មោះ [redacted] ឈ្វយជី ([redacted] Chui Zhi) ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ការដែលសភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចមិនអនុញ្ញាតឱ្យជនត្រូវចោទទាំងពីរនៅក្រៅឃុំជាបណ្តោះអាសន្ន នោះ តុលាការកំពូលពិនិត្យឃើញថា សំអាងហេតុរបស់សភាព្រហ្មទណ្ឌដែលបានលើកឡើងថា ជនត្រូវចោទទាំងពីរ ត្រូវបានចោទប្រកាន់ពីបទមជ្ឈិមដែលទោសស្របច្បាប់កំណត់ដាក់ពន្ធនាគារ ស្ថិតក្នុងលក្ខខណ្ឌនៃមាត្រា ២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាជនបរទេស ហើយការឃុំខ្លួននេះ



Scanned with CamScanner

ដើម្បីរារាំងកុំឱ្យកើតមានបទល្មើសជាថ្មី កុំឱ្យគាបសង្កត់សាក្សី ជនរងគ្រោះ កុំឱ្យមានភាពច្របូកច្របល់ដោយសារបទល្មើស និងធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមច្បាប់នោះ ជាសំអាងហេតុមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ លើសពីនេះទៀត ជនត្រូវចោទទាំងពីរ ត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ចេញដីកាដំណោះស្រាយបញ្ជូនទៅជំនុំជម្រះ និងត្រូវបានរក្សាទុកនៅក្នុងឃុំរង់ចាំតុលាការជំនុំជម្រះ តាមដីកាបង្គាប់ឱ្យរក្សាទុកជនជាប់ចោទក្នុងឃុំរង់ចាំការជំនុំជម្រះលេខ ៦៥៩៧ តព/១៩ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរ ។ ដូច្នេះ ការសុំដោះលែងនៅក្រៅឃុំជាបណ្ដោះអាសន្នរបស់ជនត្រូវចោទ លែងមានប្រយោជន៍ទៀតហើយ ឃើញថា បណ្ដឹងសាទុក្ខរបស់ជនត្រូវចោទ មិនមានមូលហេតុត្រឹមត្រូវតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៩៤ "ក្រ.III.ស.អ" ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចមកនេះ ត្រឹមត្រូវតាមច្បាប់ ។

**ហេតុដូច្នេះ**

**សម្រេច**

១.បដិសេធ បណ្ដឹងសាទុក្ខលេខ ៣៨៦ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ របស់លោក [redacted] ទី ជាមេធាវីការពារសិទ្ធិជនត្រូវចោទឈ្មោះ [redacted] ម៉ីយីង ( [redacted] Mei Ying) និងជនត្រូវចោទឈ្មោះ [redacted] ឈួយជី ( [redacted] Chui Zhi) ។

២.តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ៩៤ "ក្រ.III.ស.អ" ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ទាំងមូល ដោយគ្រាន់តែកែប្រែឈ្មោះជនត្រូវចោទពី [redacted] Mei Xing ទៅជា [redacted] Mei Ying វិញ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ។

Scanned with CamScanner